# ព្រះរាជាណាចក្រកម្ពុជា

ក្រុមហ៊ុន កូបេ យៃភៃននីស រៃស្តូរ៉ៃន **ជាតិ សាសនា ព្រះមហាក្សត្រ**

KOBF JAPANFSE RESTAURANT

# កិច្ចព្រមព្រៀង

ស្តីពីកិច្ចប្រជុំពិភាក្សាលើករណីស្នើរសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតរយៈពេល១៨ថ្ងៃ គឺចាប់ពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១

ថ្ងៃចន្ទ ទី៨រោច ខែចេត្រ ឆ្នាំជូតទោស័ក ពុទ្ធសករាជ ២៥៦៤ ត្រូវនិងថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ វេលាម៉ោងប្រាំបួនព្រឹក មានកិច្ចប្រជុំមួយនៅ ក្រុមហ៊ុន កូបេ យៃភៃននីស រៃស្តូរ៉ៃន មានអាសយដ្ឋានស្ថិតនៅភូមិគ្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាបដែលមានចំនួនកម្មករនិយោជិតសរុប ចំនួន៨១នាក់ កម្មករនិយោជិតជាស្ត្រីមានចំនួន៣៧នាក់ មាននាយកឈ្មោះ គឹម វិបុល ជនជាតិខ្មែរ ជាតំណាងក្រុមហ៊ុនកូបេ យៃភៃននីស រៃស្តូរ៉ៃន បានចូលរួមប្រជុំពិភាក្សាលើករណី ស្តីពីការស្នើរសុំព្យួរកិច្ចសន្យាការងារកម្មករ និយោជិតរយៈពេល១៨ថ្ងៃ។

ជាកិច្ចចាប់ផ្តើមលោក គឹម វិបុល ជាប្រធានអង្គប្រជុំបានបើកកិច្ចប្រជុំនិងថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅដល់អស់លោក លោកស្រីដែលបានអញ្ជើញចូលរួមប្រជុំក្នុងថ្ងៃនេះ បន្ទាប់មកលោកប្រធានអង្គប្រជុំមានមតិសម្របសម្រួលអំពី ករណីខាងលើ និងពន្យល់មូលហេតុដោយសារតែបញ្ហាការផ្ទុះមេរោគឆ្លងជាសាកល កូវីដ-១៩ ធ្វើអោយភ្ញៀវមានការធ្លាក់ចុះយ៉ាងខ្លាំង ដូចនេះក្រុមហ៊ុន កូបេ យៃភៃននីស រៃស្តូរ៉ៃន និងកម្មករនិយោជិតទាំងអស់ បានព្រមព្រៀងគ្នាដូចខាងក្រោមៈ

១-ឯកភាពព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន៣៣នាក់រយៈ១៨ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១ ដល់ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១។

២-ក្នុងអំឡុងនៃការព្យួរកិច្ចសន្យាការងារនេះ កម្មករនិយោជិតនិងទទួលបានប្រាក់ឧបត្ថម្ភរាជរដ្ឋាភិបាល ៣០ដុល្លារក្នុង១៨ថ្ងៃ ។

ខេត្តសៀមរាប,ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២០

បានឃើញ និងឯកភាព

តំណាងកម្មករនិយោជិត

តំណាងក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា
កូបេ យៃភៃននីស រៃស្តូរ៉ៃ
...សាលាក្រុងខេត្តសៀមរាប